**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៣២)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ២២ ៦០៨ នាក់ នៃរោងចក្រ សហគ្រាស ទាំង១០១ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។
  សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង១០១ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ សុក្រ ៧រោច ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ២០២០

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០

### បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍
### ចំនួន ១០១ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 57 |
| 1 | ក្រុមហ៊ុន ស៊ីន ឡាន (ខេមបូឌា)ហ្គាមេន ខមភេនីលីមីធីត | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ភី ភី អេស អ៊ី ស៊ី ឯ.ក | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ឌូហ៊ីស្ត (ខេមបូឌា) | ភ្នំពេញ |
| 4 | ក្រុមហ៊ុន វូដុង អ៊ីនដាសស្ទ្រៀល | ភ្នំពេញ |
| 5 | ក្រុមហ៊ុន អូរៀនស្ត្រីង (ខេមបូឌា)ហ្គាម៉ិន | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ជេ.អេ.ដាប់បែលយូ ឯ.ក | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ជីន ចាយ ហ៊ាន បើក ម៉ាយីង (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 8 | ក្រុមហ៊ុន ម៉ាក បើក (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 9 | ក្រុមហ៊ុន អេស.វ៉ាយ អ៊ីមប្រយឌើរី ឯ.ក | ភ្នំពេញ |
| 10 | ក្រុមហ៊ុន ម៉េងដា ហ្វូតវៀរ អ៊ីនដាស់ស្ទ្រីល | ភ្នំពេញ |
| 11 | ក្រុមហ៊ុន សាប ភ្នំពេញ ឯ.ក | ភ្នំពេញ |
| 12 | ក្រុមហ៊ុន ដាប់ប៊ីលយូ អ៊ែនដ៏ ឌី កម្ពុជា | ភ្នំពេញ |
| 13 | ក្រុមហ៊ុន សេនហ្សាន ស៊ូ ខេមបូឌា ខូអិលធីឌី | ភ្នំពេញ |
| 14 | ក្រុមហ៊ុន អេសអ៊ីភីអាយអេ (ខេមបូឌា) ហ្គាមេន | ភ្នំពេញ |
| 15 | ក្រុមហ៊ុន ធី អ័រ ស៊ី អេ ហ្គាម៉ិន | ភ្នំពេញ |
| 16 | ក្រុមហ៊ុន ជា ជា ហ៊ី ហ្គាម៉ិន (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 17 | ក្រុមហ៊ុន ម៉ាកស៍វ្ស៊ូ ថេកស្ថាយ (ខេមបូឌា) ខូអិលធីឌី | ភ្នំពេញ |
| 18 | ក្រុមហ៊ុន បាវ លី ដេ ខ្លូតស៍ | ភ្នំពេញ |
| 19 | ក្រុមហ៊ុន ផូស្តារ អ៊ិនដាស្ទៀល | ភ្នំពេញ |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 20 | ក្រុមហ៊ុន ហ្វីសាន់នី ហ្គាមេន | ភ្នំពេញ |
| 21 | ក្រុមហ៊ុន ជ័យ ជុំ អេនធើប្រាយ | ភ្នំពេញ |
| 22 | ក្រុមហ៊ុន ជាវហ៊ុយ អ៊ិនដាសស្រ្ទៀល | ភ្នំពេញ |
| 23 | ក្រុមហ៊ុន វ៉ាយវីភី ត្រេឌីង | ភ្នំពេញ |
| 24 | ក្រុមហ៊ុន ខ្វាន់ទុម អឺភែរឺល (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 25 | ក្រុមហ៊ុន សានស៊ូ ខ្លូស៊ីង (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 26 | ក្រុមហ៊ុន គ្លូរី នីត វែរ អិលធីឌី | កណ្ដាល |
| 27 | ក្រុមហ៊ុន តេហ្វ៊ូអាំប្រេឡឺខូអិលធីឌី | កណ្ដាល |
| 28 | ក្រុមហ៊ុន កៅថេក ហ្គាមេន | កណ្ដាល |
| 29 | ក្រុមហ៊ុន អេមិណិន ហ្គាម៉ិន(ខេមបូឌា) លីមីធីត | កណ្ដាល |
| 30 | ក្រុមហ៊ុន ឃ្យៀ យ៉ាង ខេមបូឌា ខូអិលធីឌី | កណ្ដាល |
| 31 | រោងចក្រផលិតកាបូប ហ៊ីលថប ឡាក់ហ្គេជ (ខេមបូឌា) ឯ.ក | កណ្ដាល |
| 32 | ក្រុមហ៊ុន វីងយីង(ខេមបូឌា)ហ្គាមេនហ្វាក់ធើរី អិលធីឌី | កណ្ដាល |
| 33 | ក្រុមហ៊ុន ណាហ្គាភីស ខបភើរេសិន លីមីធីត_1 | កណ្ដាល |
| 34 | ក្រុមហ៊ុន វីននី ហ្វេសិន | កណ្ដាល |
| 35 | ក្រុមហ៊ុន ប៊ូវយើរ ហ្គាមេនហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីតធីត | កណ្ដាល |
| 36 | ក្រុមហ៊ុន ស្មាតស៊ើតស៍ ហ្គាមេន មេនូហ្វេកធើរីង (ខេមបូឌា) | កំពង់ស្ពឺ |
| 37 | ក្រុមហ៊ុន ព្រេ្គត ភីស លីមីធីត | កំពង់ស្ពឺ |
| 38 | ក្រុមហ៊ុន សូអា ផ្លាសថយ (ខេមបូឌា) ខូ អិល ធី ឌី | កំពង់ស្ពឺ |
| 39 | ក្រុមហ៊ុន យី. ហ្គ័ង. អ៊ីនធើណេសិនណល ខូអិលធីឌី | កំពង់ស្ពឺ |
| 40 | ក្រុមហ៊ុន ហ្គាថា អ៊ិនធើណេសិនណល ខូអិលធីឌី | កំពង់ស្ពឺ |
| 41 | ក្រុមហ៊ុន លីវ តាន អ៊ីនធើណេសិនណល ខេមបូឌាខូអិលធីឌី | កំពង់ស្ពឺ |
| 42 | ក្រុមហ៊ុន សាប្រ៊ីណា (ខេមបូឌា) ហ្គាម៉ិន ម៉ែនញ៉ូហ្វាក់ធីរីន ខប | កំពង់ស្ពឺ |
| 43 | ក្រុមហ៊ុន ស៊ីអិនឌីហ្វ្រី អិនធើណេសិនណល (ខេអេច) ឯ.ក | កំពង់ស្ពឺ |
| 44 | ក្រុមហ៊ុន ថេនថេក អ៊ិនដាសស្រ្ទៀល ខូ អិលធីឌី | កំពង់ស្ពឺ |
| 45 | ក្រុមហ៊ុន សូឡាម៉ូដា (ខេមបូឌា) ហ្គាមេន ខូអិលធីឌី | តាកែវ |
| 46 | ក្រុមហ៊ុន ភើហ្វិកវីសិន ហ្វេសិន ( ខេមបូឌា) ឯ.ក | តាកែវ |
| 47 | ក្រុមហ៊ុន ចឹងស្រេង អ៊ិនដាសស្រ្ទៀល | តាកែវ |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 48 | ក្រុមហ៊ុន ប្រាយ ហ្គាស់ស៊ីង ឯ.ក | តាកែវ |
| 49 | ក្រុមហ៊ុន ហាផ៌រអិនធើណេសិនណល(ខេមបូឌា)ឯ.ក | តាកែវ |
| 50 | ក្រុមហ៊ុន ជាតាន់ អិនដាសស្ទ្រៀល ឯ ក ស្រុកព្រៃឈរ ខេត្តកំពង់ចាម | កំពង់ចាម |
| 51 | ក្រុមហ៊ុន ហឺវ៉ាយហ្សិន អេវដរ(ខេមបូឌា)ខូ,.អិលធីឌី | កំពង់ឆ្នាំង |
| 52 | ក្រុមហ៊ុន យឺងម៉េកឃើ(ខេមបូឌា)ហ្វូតវែរ | ស្វាយរៀង |
| 53 | ក្រុមហ៊ុន ស៊ីកូ (ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |
| 54 | ក្រុមហ៊ុន អ៊ីលីត (ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |
| 55 | ក្រុមហ៊ុន សោន 868 ឯ.ក | ស្វាយរៀង |
| 56 | ក្រុមហ៊ុន ហ្សូន (ខេមបូឌា) ត្រាវែលលីង & ហៃនប៊ែក ឯ.ក | ព្រះសីហនុ |
| 57 | ក្រុមហ៊ុន ធី.ខេ ហ្គាមេន ស៊ីសុផុន | បន្ទាយមានជ័យ |
| **ខ. វិស័យទេសចរណ៍** | | **44** |
| 58 | ក្រុមហ៊ុន បាអាតហ្គុត ឯ.ក | ភ្នំពេញ |
| 59 | ក្រុមហ៊ុន ដារ៉ា អ៊ែរផត ហូថេល | ភ្នំពេញ |
| 60 | សណ្ឋាគារ ហ្គាឌិន ស៊ីធី ហូថេល | ភ្នំពេញ |
| 61 | សណ្ឋាគារ រ៉េស៊ីដង់ សុខា ភ្នំពេញ | ភ្នំពេញ |
| 62 | ក្រុមហ៊ុន វើលដ៍ ផប ត្រាវែល-ធួរ គ្រុប | ភ្នំពេញ |
| 63 | សណ្ឋាគារ ភ្នំពេញ អេរ៉ា ហូថេល ឯ.ក | ភ្នំពេញ |
| 64 | ក្រុមហ៊ុន ឆេនណល សាយថ៍ ឌីស្ទីប្យូសិន | ភ្នំពេញ |
| 65 | ក្រុមហ៊ុន ភី ធី អ៊ិម ត្រាវែល អ៊ែន ធួរ | ភ្នំពេញ |
| 66 | ក្រុមហ៊ុន កាំបូឌីយ៉ាណា អិនវេស្តមេនធ៍ (ភ្នំពេញ) ភីធីអ៊ី អែលធីឌី | ភ្នំពេញ |
| 67 | ក្រុមហ៊ុន វើលដ៍ ដាយនីង លីមីធីត | ភ្នំពេញ |
| 68 | សណ្ឋាគារ អូឡាំព្យា ស៊ីធី ហូថេល | ភ្នំពេញ |
| 69 | ក្រុមហ៊ុន អិល&អិម បាសាក់ រីវើរ ខូ អិលធីឌី | ភ្នំពេញ |
| 70 | ក្រុមហ៊ុន អលមិន ខូ អិលធីឌី | ភ្នំពេញ |
| 71 | ក្រុមហ៊ុន ហ្វ៊ូដឡាយហ្វ៍ | ភ្នំពេញ |
| 72 | ក្រុមហ៊ុន ឡឺ ប្រេស៊ីដង់ អូតែល-កូបេ | ភ្នំពេញ |
| 73 | ក្រុមហ៊ុន អេមខេត (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 74 | សណ្ឋាគារសុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |

| ល.រ | ឈ្មោះគេហដ្ឋាន សណ្ឋាគារ | រាជធានី ខេត្ត |
|---|---|---|
| 75 | ក្រុមហ៊ុន កូបេ រ៉ៃយែនទីស រីសូរ៉ែន | សៀមរាប |
| 76 | ក្រុមហ៊ុន ខមមិនអេរៀ (ខេមបូឌា) | សៀមរាប |
| 77 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 78 | សណ្ឋាគារ អូរៀនថល ដេ7 | សៀមរាប |
| 79 | ក្រុមហ៊ុន ស៊ីវ៉ាយ-អេសអ ហូថេល ហ្វ្រេន ឡាយអិន ឯ.ក | សៀមរាប |
| 80 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |
| 81 | ក្រុមហ៊ុន គ្រិះស្ថាន ដាញប៊ីយ៉ន ស៊ីវីស | សៀមរាប |
| 82 | ក្រុមហ៊ុន ដឺឃីតឈិនឆាយល | សៀមរាប |
| 83 | ក្រុមហ៊ុន អាហ្សូណា កាហ្វេធើរ៉ា | សៀមរាប |
| 84 | ក្រុមហ៊ុន អង្គរកែលេសរីហ្សត និងស្ប៉ា | សៀមរាប |
| 85 | ក្រុមហ៊ុន មុទិតា រីសត & ស្ប៉ា | សៀមរាប |
| 86 | ក្រុមហ៊ុន ហ្គោលដេន ទ្រី ព្រីនស៍ ហូថែល និងស្ប៉ា | សៀមរាប |
| 87 | ក្រុមហ៊ុន ខ្មែរអង្គរហូថែលកូអិលធីឌី | សៀមរាប |
| 88 | ក្រុមហ៊ុន ដំរីអង្គរ ខូ អិលធីឌី | សៀមរាប |
| 89 | ក្រុមហ៊ុន ផូរិចអេស៊ា | សៀមរាប |
| 90 | ក្រុមហ៊ុន ប៉ូរ ឃ្វីហ្ស៊ីន | សៀមរាប |
| 91 | ភោជនីយដ្ឋាន នារីខ្មែរ | សៀមរាប |
| 92 | ក្រុមហ៊ុន ម៉េម៉ឺអង្គរ (ខេមបូឌា) | សៀមរាប |
| 93 | សណ្ឋាគារតាព្រហ្ម | សៀមរាប |
| 94 | ក្រុមហ៊ុន អ៊ីបេន ទ្រី ហាត់ | សៀមរាប |
| 95 | សណ្ឋាគារ ម៉ាល់ បើរី បូទិច អូតែល | សៀមរាប |
| 96 | សណ្ឋាគារ អង្គរមិរ៉ាខល រីហ្សត និង ស្ប៉ា | សៀមរាប |
| 97 | សណ្ឋាគារ បាយ័ន អេរ៉ា ហូថែល ឧបភើរសិន | សៀមរាប |
| 98 | សណ្ឋាគារ តារា អង្គរ | សៀមរាប |
| 99 | សណ្ឋាគារ ប៉ាស៊ីហ្វិក | សៀមរាប |
| 100 | ភោជនីយដ្ឋាន ចាន់រីទ្រី | សៀមរាប |
| 101 | ក្រុមហ៊ុន ថ្មរូង ឌីវេឡុបមេន | ព្រះសីហនុ |